# រឿង ដើមរល្ហួសមាស

---

រល្ហួសមាស ជាសន្តានដើមផ្កាមួយប្រភេទ ប៉ុន្តែចម្លែកត្រង់ដើមនេះ គ្មានផ្កាទេ គេដាំយកលម្អត្រង់ស្លឹកវានោះឯង ។ ស្លឹករល្ហួសមាស ផ្លាស់ប្តូរបានជាបីពណ៌ក្នុងមួយឆ្នាំ គឺដំបូងពណ៌ស មាន

សណ្ឋានដូចស្លឹកចម្ប៉ា, អស់រយៈ ២-៣ ខែ ស្លឹកនេះប្រែជាក្រហមឆ្អៅដូចផ្កាក្ងោក លុះបាន ៣-៤ ខែ តមកទៀត ស្លឹកដដែលនេះ ក៏ប្តូរពណ៌បៃតងចាស់ដូចស្លឹកឈើធម្មតាវិញ ។ ដោយសារតែចេះផ្លាស់ប្តូរពណ៌ល្អមើលប្លែកពីដើមឈើដទៃ ៗ ទៀតដូចនេះហើយ បានជាគេដាំរល្ហួសមាសនេះ នៅពីមុខផ្ទះ ឬក្នុងសួនសាធារណៈផ្សេង ៗ ។

មិនតែប៉ុណ្ណោះ ចាស់ទុំតែងនិទានពីរឿងព្រេងជាប្រវត្តិដើមរុក្ខជាតិនេះ យ៉ាងកម្សត់ នាំឲ្យអ្នកផងទាក់ចិត្តនឹងដើមនេះ កាន់តែខ្លាំងឡើង ។
រឿងនោះមានសេចក្តីដំណាលថា: មានបុរសម្នាក់ឈ្មោះកុល្លិយៈ មានប្រពន្ធឈ្មោះនាងកែវកេសី មានកូនស្រីម្នាក់ឈ្មោះនាងកុលកេសី ។ ស្តេចទ្រង់ប្រទានងារជាមេស្រុក សម្រាប់ត្រួតត្រាលើប្រជា

រាស្ត្រទូទៅ ។ មានបុរសកម្សត់ម្នាក់ទៀត នៅនាក្បែរលំនៅមេស្រុកនេះ មានរបររកស៊ីធ្វើស្រែ ។ ក្នុងពេលដែលប្រពន្ធមានផ្ទៃពោះគ្រប់ទសមាស ក៏ប្រសូតិបុត្រប្រុសមួយនៅក្នុងស្រែ ដែលនាងកំពុងច្រូតស្រូវ , អ្នកផងទាំងពួងដែលនៅចាំស្រូវស្រែផងគ្នា ក៏ឲ្យឈ្មោះកូននោះថា ចៅកុដុម្ពីក៍កុមារ ។ កុដុម្ពីក៍កុមារកាលចម្រើនវ័យវឌ្ឍនាការបានអាយុ ១៦ ឆ្នាំ ក៏ប្រកបដោយរូបឆោមយ៉ាងឆើត គួរជាទីចាប់អារម្មណ៍នៃស្រីផងទាំងពួង ។ ឯនាងកុលកេសីជាបុត្រីកុល្លិយបុរស ក៏មានសម្រស់គួរចេតនាដែរ ។ ទាំងពីរនាក់ បានលបលួចស្នេហារវាងគ្នានឹងគ្នា រហូតទាល់តែដាច់ចិត្តនាំគ្នារត់ចេញពីស្រុកកំណើត ដោយខ្លាចឪពុកម្តាយទាំងពីរខាងធ្វើទោស ។

ទាំងពីរនាក់ប្តីប្រពន្ធ ខំដើរផងរត់ផងកាត់ព្រៃព្រឹក្សា ប្រទះហ្វូងម្រឹគាគួរឲ្យភ័យខ្លាច ទាំងយប់ទាំងថ្ងៃឥតឈប់ឈរ បានទៅដល់ខេត្តក្រៅ មួយជាជនបទដាច់ស្រយាលឈ្មោះកាសី ។ អ្នកស្រុកកាសី

នេះ គ្មានអ្នកណាម្នាក់ រកស៊ីដោយសម្មាអាជីវៈទេ, ម្នាក់ ៗ គិតតែពីលួចប្លន់កាប់សម្លាប់ដណ្តើមគេ យកទាំងភ្នែកស្រស់ ៗ ។ បើគេមើលទៅក្នុងផ្ទះជនទាំងនោះ គេឃើញតែកន្សែងយន្ត-មន្ត អាគម បាយសី ពេញល្វែងផ្ទះ ។ ទាំងមេស្រុកនៅស្រុកនោះ ក៏ចូលដៃជើងជាមួយពួកចោរនោះដែរ ។ ឯកុដុម្ពីក៍និងកុលកេសី បានទៅដល់ស្រុកនោះភ្លាម ក៏ត្រូវពួកចោរ ហានេឃ្មុំ ចាប់កុដុម្ពីក៍បាន ប៉ុន្តែនាងកុលកេសីជាប្រពន្ធ យកចិញ្ចៀនទៅឲ្យមេស្រុក ដើម្បីសុំអង្វរឲ្យមេស្រុកជួយយ៉ាងណាឲ្យពួកចោរដោះលែងប្តីនាងមកវិញ ។

មេស្រុកបានទៅនិយាយនិងក្រុមចោរដោយសម្អាងថា: ជាញាតិសាលោហិតរបស់ខ្លួន ចោរក៏ដោះលែងឲ្យកុដុម្ពីក៍រួចខ្លួនហើយទាំងពីរនាក់ប្តីប្រពន្ធ ក៏បានសុំលោកមេស្រុកនិងប្រពន្ធគាត់ធ្វើជាឪពុកម្តាយធម៌ ។ មេស្រុកនិងប្រពន្ធគាត់ ត្រេកអរណាស់ ព្រោះគាត់គ្មានកូន, បានកូនទាំងពីរនាក់នេះ នឹកថានឹងបានបន្តពូជធារនិងជាអ្នកទទួលមត៌កផង។ គាត់ស្រឡាញ់កុដុម្ពីក៍និងនាងកុលកេសី ទុកដូចជាកូនបង្កើត ។ មិនយូរប៉ុន្មានមេស្រុកនិងភរិយាក៏ស្លាប់ទៅ ។ កុដុម្ពីក៍និងនាងកុលកេសី ក៏ទទួលមត៌កអំពីឪពុកម្តាយធម៌ បានឡើងជាមេស្រុកជំនួសឪពុកម្តាយ ។

ចាប់ពីថ្ងៃនោះ កុដុម្ពីក៍និងនាងកុលកេសី បានឡើងជាអ្នកមានស្តុកស្តម្ភ ចេញមុខចេញមាត់មានខ្ញុំកំដរស្រីប្រុសបម្រើឆ្វេង-ស្តាំឥតខ្វះ ទាំងក្រុមចោរដែលធ្លាប់តែរកស៊ីលួចប្លន់ក៏បាក់បបខ្លបខ្លាច, លែងរកស៊ីលួចប្លន់ដូចមុនទៀត ត្រឡប់មកស៊ីតាមធម្មតាវិញ ។ តមក កុដុម្ពីក៍បាននាមថា:កុលកោដិកុដុម្ពីកសេដ្ឋីមាននាមល្បីល្បាញខាងមានសម្បត្តិច្រើន ។

កុលកោដិកុដុម្ពីកសេដ្ឋី បានរួមសម្ពពជាមួយនាងកុលកេសី បានបុត្រីមួយឈ្មោះនាងកុមារិកា ដោយនាងបានសាងបារមីជាព្រះជននីពោធិសត្វ កាលពីជាតិមុន នាងក៏ប្រកបដោយរូបឆោមយ៉ាងស្រស់ឆើតឆាយលើសកុមារិកាឯទៀត ៗ ក្នុងស្រុក, ហើយនាងមានចិត្តជាទិព្វទៀតផង នាងគិតយ៉ាងណានឹងបានសម្រេចយ៉ាងនោះដូចប្រាថ្នា ។ លុះនាងកុមារីមានព្រះជន្ម ៧ វស្សា, មានស្រីមេម៉ាយចិត្តឫស្យាម្នាក់ឈ្មោះនាងកាឡី មានកូនស្រី ២ នាក់ គឺ: នាងចន្ទី និងនាងចន្ទនី សុទ្ធតែជាស្រីកាឡកណ្ណីដូចគ្នា ។ នាងមេម៉ាយកាឡីនេះមានបងស្រីម្នាក់ទៀតឈ្មោះកាឡីនីយា ។

មេកាឡីជាស្រីមេម៉ាយមានចិត្តសាវានឹកចង់បានប្តី ដោយបានឮល្បីថា: កុលកោដិកុដុម្ពីសេដ្ឋីមានទ្រព្យច្រើន ក៏ទៅប្រលោមលួងលោមទាល់តែកុលកោដិកុដុម្ពីកសេដ្ឋីព្រមស្នេហាជាមួយ ដោយភ្លេចនឹកដល់នាងកុលកេសី ជាស្រីប្រកបដោយលក្ខណាត្រឹមត្រូវនោះទៅ ។

មេកាឡី កាលដែលបានកុលកោដិកុដុម្ពីក៍ ជាស្វាមីហើយក៏ច្រណែនឈ្នានីស ចាក់រុករករឿងលើកកំហុសដាក់ទៅលើនាងកុលកេសីប្រពន្ធដើម ថាជាស្រីមានសហាយស្មន្ធអន្ធការផ្សេង ៗ រៀងរាល់ថ្ងៃមិនចេះឈប់ឈរសោះ, ទាល់តែកុលកោដិកុដុម្ពីក៍ជឿតាមសម្តីរបស់ខ្លួន ។

ថ្ងៃមួយ កុលកោដិកុដុម្ពីក៍ នាំនាងកុលកេសីទៅបង់សំណាញ់ក្នុងទន្លេ កំពុងតែបង់សំណាញ់ ស្រាប់តែគាត់រករឿងលើកកំហុសដាក់លើប្រពន្ធថាមានសហាយ ទោះបីនាងកុលកេសី និយាយតាមត្រង់យ៉ាងណា ក៏កុដុម្ពីក៍មិនជឿ ក៏កើតជាជម្លោះក្នុងកណ្តាលជលសា, ពេលនោះកុដុម្ពីក៍ក៏វាយនាងកុលកេសីទម្លាក់ទៅក្នុងទឹកស្លាប់ទៅ ក៏ទៅកើតជាត្រីដំរី ដោយអំណាចផលានិសង្សរបស់នាងកុមារិកាជាកូនដែលនាងមានចិត្តជាទិព្វ ។

លុះកុលកោដិកុដុម្ពីក៏ ត្រឡប់មកវិញ នាងកុមារិកាក៏សួររកមាតា ។ ឪពុកឆ្លើយថា: គតបានដឹងរឿងអ្វីសោះក្នុងរឿងនេះ, តែនាងកុមារិកាក៏នៅសួរជជីករកឫសគល់ថា: ខ្ញុំឃើញច្បាស់ជាម៉ែទៅជា

មួយឪហើយម្តេចក៏ឪឆ្លើយថា មិនដឹងយ៉ាងនេះ ? ។

នាងកុមារិកាសង្ស័យក៏ដើរទៅកំពង់ ដើម្បីតាមរកមើលមាតា ទៅដល់ក៏ទូញយំរៀបរាប់ពីដំណើរបាត់មាតា ។ ត្រីដំរីជាមាតាឮ ក៏ងើបក្បាលពីក្នុងទឹកមកនិយាយរឿងប្រាប់កូនស្រីតាំងពីដើមដល់ចប់

ហើយនិយាយថា: ម្តាយគ្មានអីស៊ីទេ ម្តាយឃ្លានណាស់ ចូរកូនរកចំណីឲ្យម្តាយស៊ីផង ។នាងកុមារិកាក៏សន្យាថានិងយកកន្ទក់និងចុងអង្ករទៅឲ្យស៊ីរៀងរាល់ថ្ងៃ ។ តាំងពីថ្ងៃនោះមក នាងកុមារិកាបាននាមថ្មីថា " មរណមាតា " ។ មេកាឡីក្រោយដែលបានដឹងថា: ត្រីដំរីនោះជាមាតានាងមរណមាតាក៏ឲ្យចន្ទី-ចន្ទនីជាកូន ទៅចាប់យកមកសម្លាប់ធ្វើម្ហូបស៊ីទៀត, តែដោយហេតុនាងមរណមាតាមានផលានិសង្សច្រើន ក៏បណ្តាលឲ្យកណ្តុរសពាំបានស្រកាត្រីដំរីពីរ ទុកឲ្យនាងមរណមាតាដឹង ។ នាងមរណមាតាយកស្រកាត្រីពីរនោះទៅកប់ទុកក្នុងដី ក៏ស្រាប់តែដុះឡើងជាដើមត្រប់ ហើយនាងទំនុកបម្រុងដើមត្រប់ ធ្វើវត្តប្រតិបត្តិរៀងរាល់ថ្ងៃ ។ មេ កាឡីដឹងថាដើមត្រប់ជាមាតានាងមរណមាតា ក៏ឲ្យគេយកដើមត្រប់ទាំងឫសទាំងគល់ទៅបុកកម្ទេចចោល, តែពេលនោះមានឆ្មាមួយ បានពាំឫសពីរសរសៃទុកឲ្យនាងមរណមាតា ។ នាងយកឫសត្រប់ពីរទៅដាំក៏កើតជាដើមរលួសពីរដើម រលួសនេះ ប្លែកពីរលួសធម្មតា គឺមានស្លឹកនោះប្រកបដោយពណ៌ឆ្អិនឆ្អៅ ហើយដើមនោះក៏គ្មានបន្លាដូចរលួសធម្មតាដែរ ។

នៅថ្ងៃមួយ ព្រះចៅផែនដីព្រះអង្គទ្រង់យាងមកប្រពាតព្រៃ, ពេលថ្ងៃក្តៅ ព្រះអង្គក៏យាងចូលទៅសម្រាកព្រះកាយក្រោមម្លប់ដើមរលួសមួយគូនោះ ។ មុននឹងទ្រង់ចេញចាកទីនោះទៅ ព្រះអង្គទ្រង់

ត្រាស់សួររកម្ចាស់ដើមឈើចម្លែកនេះ ដើម្បីសុំគាស់យកទៅដាំឯក្នុងព្រះរាជវាំង ។ ស្តេចទ្រង់យល់រូបឆោមនាងមរណមាតាដ៏ស្រស់បស់ ជាទីគាប់ព្រះទ័យហើយព្រះអង្គក៏ត្រាស់សុំដើមឈើនោះ, នាងក៏ព្រមថ្វាយ ។ តែពួកអាមាត្យខំជីកគាស់យ៉ាងណាក៏មិនរបើករលើងដើមនោះពីដីសោះ, លុះព្រះអង្គត្រាស់សួរនាងមរណមាតា នាងក៏សំពះអធិដ្ឋានដល់ទេវធីតាជាមាតាដែលថែដើមនោះ ស្រាប់តែដើមរលួសផុសពីដីអណ្តែតឡើងទៅដុះនៅក្នុងផើងមាស របស់ព្រះមហាក្សត្រ នៅឯមុខព្រះមហាប្រាសាទ ។

ព្រះអង្គក៏ទ្រង់ត្រាស់ហៅនាងមរណមាតា ឲ្យចូលទៅក្នុងព្រះរាជវាំងហើយអភិសេកជាមហេសីឡើង, ឯផ្កានោះឲ្យនាមហៅថា " ផ្ការលួសមាស " ព្រោះបានអណ្តែតមកស្ថិតនៅក្នុងផើងមាស ហើយ

មានពណ៌ស្លឹកនោះគ្រចះគ្រចង់ណាស់ផង ។